01032023

E307/1/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 10 / 2014
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីសម្រេចលើសំណើរួមសុំឲ្យសម្រេច*សាជាថ្មីឡើងវិញ*លើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

១. អង្គជំនុំជម្រះបានទទួលសំណើរួមមួយពីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ដោយបានស្នើសុំអង្គជំនុំជម្រះឲ្យពិចារណា*សាជាថ្មីឡើងវិញ* លើសេចក្តីសម្រេចលើកមុនរបស់ខ្លួន (ឯកសារ E307/1) ដែលនៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានសម្រេចថា វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងភ័ស្តុតាងថ្មី ត្រូវអនុវត្តចំពោះគ្រប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ និងឯកសារទាំងអស់ដែលភាគីបានស្នើសុំបន្ទាប់ពីសវនាការបឋម កាលពីខែ មិថុនា ឆ្នាំ ២០១១ (ឯកសារ E307/1/1 កថាខណ្ឌ ៩ ("សំណើសុំរួម"))។ សហព្រះរាជអាជ្ញា និងសហមេធាវី នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំបន្ថែមឲ្យអង្គជំនុំជម្រះបញ្ជាក់ថា "ភ័ស្តុតាងថ្មី" នៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងសំដៅលើភ័ស្តុតាងទាំងឡាយណាដែលពុំមាននៅក្នុងសំណុំរឿង ឬនៅក្នុងបញ្ជីរបស់ភាគីអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ពុំបានឆ្លើយតបនោះទេ។

២. សំណើសុំរួមសន្និដ្ឋានថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមនៅក្នុងសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E301/9/1/1/3 (សេចក្តីសម្រេចរបស់ អ.ជ.ត.ក)) ដែលក្នុងនោះបានបញ្ជាក់បំភ្លឺថាសញ្ញាណនៃការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានចាត់ទុកជាកាលៈទេសៈថ្មីមួយដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យឡើងវិញលើពេលវេលានៃភាពអាចអនុវត្តទៅបាននៃវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង។

៣. យោងតាមការបកស្រាយនៅក្នុងសំណើសុំរួម សេចក្តីសម្រេចរបស់ អ.ជ.ត.ក បានសម្រេចថា ការបំបែកកិច្ចដំណើរការនីតិវិធីបង្កើតជាសំណុំរឿងដាច់ពីគ្នា និងផ្សេងពីគ្នា ដែលតម្រូវឱ្យមានការកំណត់ដាច់ដោយឡែកពីគ្នាស្តីពីសិទ្ធិផ្សេងៗដែលទាក់ទងនឹងនីតិវិធីរបស់ភាគីនានានៅក្នុងសំណុំរឿងនីមួយៗ។ សំណើសុំរួមនេះអះអាងថា វិធាន ៨០ នៃវិធានផ្ទៃក្នុង (ទាក់ទងនឹងការរៀបចំសវនាការ) និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវយកមកអនុវត្តដាច់ដោយឡែកពីគ្នានៅក្នុងការជំនុំជម្រះក្តីនីមួយៗ។ ហេតុដូច្នេះ សំណើសុំរួមនេះសន្និដ្ឋានថា សវនាការបឋមបន្ថែមនៅក្នុងសំណុំរឿង ០០២/០២ កាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ គឺជាកាលបរិច្ឆេទដែលមានអានុភាពសម្រាប់ការសម្រេចថាតើ ភស្តុតាងណាមួយគឺជាភស្តុតាង "ថ្មី"។ សំណើសុំរួមនេះបានលើកឡើងថា មានតែសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ និងឯកសារដែលបានស្នើឡើងក្រោយសវនាការបឋមបន្ថែមតែប៉ុណ្ណោះ ដែលចាំបាច់ត្រូវបំពេញលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ម្យ៉ាងវិញទៀត សំណើសុំរួមនេះសុំឱ្យអង្គជំនុំជម្រះប្រកាសថា "ភស្តុតាងថ្មី" សំដៅលើភស្តុតាងទាំងឡាយណាដែលពុំមាននៅក្នុងសំណុំរឿង ឬ នៅក្នុងបញ្ជីរបស់ភាគីអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង (ឯកសារ E307/1/1 កថាខណ្ឌ ១០, ១២-១៣, ២២ (ខ))។

៤. វិធានផ្ទៃក្នុងពុំមានចែងអំពីនីតិវិធីសម្រាប់ការពិចារណាឡើងវិញ លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ព្រោះនីតិវិធីបែបនេះនឹងបណ្តាលឱ្យមានការដាក់បណ្តឹងជាបន្តបន្ទាប់ពុំចេះចប់ពុំចេះហើយលើបញ្ហាដដែលៗ (ឯកសារ E238/11/1 កថាខណ្ឌ ៧)។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះធ្លាប់បានពិចារណាសាជាថ្មីលើសំណើសុំរបស់ភាគី ក្នុងករណីដែលអង្គហេតុថ្មី ឬ កាលៈទេសៈថ្មីតម្រូវឱ្យធ្វើដូច្នេះ (ឯកសារ E282/2/1/2 កថាខណ្ឌ ៣)។ អង្គជំនុំជម្រះពិចារណាឃើញថា សេចក្តីសម្រេចរបស់ អ.ជ.ត.ក បង្កើតជាកាលៈទេសៈថ្មីមួយដែលតម្រូវឱ្យមានការពិចារណាសាជាថ្មីលើសេចក្តីសម្រេចលើកមុនរបស់ខ្លួន។

ទោះបីជា ទស្សនៈដែលលើកឡើកថា ការបំបែកកិច្ចដំណើរការនីតិវិធីបង្កើតជាការជំនុំជម្រះដាច់ដោយឡែកពុំមែនជាទស្សនៈថ្មីក៏ដោយ (អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបញ្ជាក់ពីបញ្ហានេះជូនដល់ភាគីនាពេលមុនរួចហើយ៖ ឯកសារ E307/1 កថាខណ្ឌ ២) ក៏សេចក្តីសម្រេចរបស់ អ.ជ.ត.ក បានពន្យល់លម្អិតជាក់លាក់រួចហើយ អំពីការអនុវត្តជាក់ស្តែងនៃការបំបែកកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ករណីនេះទំនងជាអាចធ្វើឱ្យលេចឡើងនូវបញ្ហាថ្មីៗសម្រាប់យកមកពិចារណាទាក់ទងនឹងការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

៥. វាជាមូលដ្ឋានរួមដែលថា ការបំបែកកិច្ចដំណើរការនីតិវិធីបង្កើតជាសំណុំរឿងដាច់ពីគ្នា និងផ្សេងពីគ្នា។ សំណើសុំរួមនេះ ផ្តោតលើផលវិបាកមួយក្នុងចំណោមផលវិបាកផ្នែកនីតិវិធីនានាដែលកើតចេញពីករណីនេះ ពោលគឺ ការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

៦. សំណើសុំរួមសន្និដ្ឋានថា សេចក្តីសម្រេចរបស់ អ.ជ.ត.ក "បានសម្រេចថា ការបង្កើតឡើងនូវសំណុំរឿងដែលដាច់ពីគ្នា គឺតម្រូវឱ្យមានការសម្រេចដាច់ដោយឡែកពីគ្នាស្តីពីសិទ្ធិផ្សេងៗដែលទាក់ទងនឹងនីតិវិធីរបស់ភាគីនានានៅក្នុងសំណុំរឿងនីមួយៗ" (ឯកសារ E307/1/1 កថាខណ្ឌ ១២)។ តាមការពិត សេចក្តីសម្រេចរបស់ អ.ជ.ត.ក បានកំណត់ថា "បញ្ហានៃការជំនុំជម្រះប្រកបដោយយុត្តិធម៌នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី និងការឃុំខ្លួនបណ្តោះអាសន្នមុនការជំនុំជម្រះ ត្រូវតែធ្វើការវាយតម្លៃដោយឡែកសម្រាប់សំណុំរឿងព្រហ្មទណ្ឌនីមួយៗដែលត្រូវបានបង្កើតឡើងដោយសារការបំបែកនេះ" (ឯកសារ E301/9/1/1/3 កថាខណ្ឌ ៤៤)។ ទោះបីជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង គួរអាចអនុវត្តបានចាប់តាំងពីការចាប់ផ្តើមជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ មកម្លេះ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបញ្ជាក់យ៉ាងច្បាស់នាពេលមុនរួចហើយ អំពីជំហររបស់ខ្លួនថា ការជំនុំជម្រះនេះបានចាប់ផ្តើមនៅក្នុងឆ្នាំ ២០១១ (ឯកសារ E307/1 កថាខណ្ឌ ២)។ បច្ចុប្បន្ន ជំហរនេះត្រូវបានជំទាស់តវ៉ានៅក្នុងសំណើសុំរួម។

៧. សំណើសុំរួមសន្និដ្ឋានថា ការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមជាមួយនឹងសវនាការបឋមបន្ថែមកាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤។ ការសន្និដ្ឋានដូច្នេះនៅក្នុងសំណើសុំរួមគឺតាមរយៈការសន្មតថា អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគីដាក់បញ្ជីឈ្មោះសាក្សី និងឯកសារសម្រាប់រឿងក្តីនីមួយៗរៀងៗខ្លួនដាច់ដោយឡែក ពោលគឺ នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ សម្រាប់សំណុំរឿង ០០២/០១ ("បញ្ជីឆ្នាំ ២០១១") និងនៅថ្ងៃទី

០៨ ខែ មេសា ឆ្នាំ ២០១៤ សម្រាប់សំណុំរឿង ០០២/០២ (ឯកសារ E307/1/1 កថាខណ្ឌ ១៣)។ ការសន្និដ្ឋានដូចនេះ គឺពុំមានមូលដ្ឋានត្រឹមត្រូវឡើយ។ នៅក្នុងឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគីដាក់បញ្ជីរបស់ពួកគេរៀងៗខ្លួនសម្រាប់សំណុំរឿង ០០២ កាលពីថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ដោយការបង្គាប់នោះធ្វើឡើងនៅមុនពេលពិចារណាលើការបំបែកកិច្ចដំណើរការនីតិវិធី និងនៅមុនពេលបទប្បញ្ញត្តិស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានដាក់បញ្ចូលនៅក្នុងវិធានផ្ទៃក្នុង (អនុម័តនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១)។ បញ្ជីទាំងនេះ គឺសម្រាប់រឿងក្តីទាំងមូលនៅពេលនោះ ដែលរួមបញ្ចូលទាំងសាក្សី និងឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ នាពេលបច្ចុប្បន្នផងដែរ។ ទស្សនៈយល់ឃើញនេះត្រូវបានគាំទ្របន្ថែមដោយវិធាន ៨០(១) នៃវិធានផ្ទៃក្នុង ដែលបានដាក់កាលបរិច្ឆេទកំណត់សម្រាប់ការដាក់បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ អនុលោមតាមដីកាដំណោះស្រាយ។ ហេតុដូច្នេះ បញ្ជីឆ្នាំ ២០១១ ពុំត្រូវបានដាក់ជាក់លាក់ ឬ ដាក់សម្រាប់តែសំណុំរឿង ០០២/០១ តែប៉ុណ្ណោះនោះទេ។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋាននៅក្នុងសំណើសុំរួមត្រង់ចំណុចនេះគ្មានមូលដ្ឋានឡើយ។

៨. សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្របគ្នានឹងជំហរនេះ។ សេចក្តីសម្រេចនោះ បានលើកឡើងថា សំណុំរឿង ០០២/០១ ពុំត្រូវបានបំបែកជាផ្លូវការរហូតដល់ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯកសារ E301/9/1/1/3 កថាខណ្ឌ ៧៤)។ ហេតុដូច្នេះ ដីកាបង្គាប់ឱ្យដាក់បញ្ជីឈ្មោះសាក្សី ចុះកាលពីថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ គឺសម្រាប់សំណុំរឿង ០០២ ទាំងមូលដែលរួមបញ្ចូលទាំងសំណុំរឿងដែលក្រោយមកក្លាយជាសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ផងដែរ។ លើសពីនេះ អនុលោមតាមសេចក្តីសម្រេចរបស់ អ.ជ.ត.ក សវនាការទាំងឡាយរហូតមកដល់ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ បានធ្វើឡើងជាផ្នែកមួយនៃសំណុំរឿង ០០២ ហើយពាក់ព័ន្ធនឹងភស្តុតាងរួមសម្រាប់ទាំងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ (ឯកសារ E301/9/1/1/3 កថាខណ្ឌ ៤៣)។

៩. សំណើសុំរួមទំនងជាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងត្រូវបង្គាប់ឱ្យភាគីដាក់បញ្ជីដោយឡែកៗពីគ្នាសម្រាប់ការជំនុំជម្រះនីមួយៗនៅក្នុងសំណុំរឿង ០០២ (ឯកសារ E307/1/1 កថាខណ្ឌ ១២-១៣)។ សេចក្តីសន្និដ្ឋាននេះពុំមានមូលដ្ឋាននៅក្នុងវិធានផ្ទៃក្នុង ឬ សេចក្តីសម្រេចរបស់ អ.ជ.ត.ក នោះទេ។ បញ្ជីឆ្នាំ ២០១១ រួមមានឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ និងឯកសារសម្រាប់សំណុំរឿង ០០២ ទាំងមូល ហេតុដូច្នេះ បញ្ជីទាំងនេះគឺសម្រាប់

រឿងក្ដីទាំងពីរ ដែលក្រោយមកត្រូវបានបង្កើតឡើងតាមរយៈការបំបែកកិច្ចដំណើរការនីតិវិធី។ ទោះបីជាបញ្ជីឆ្នាំ ២០១១ មានវិសាលភាពធំធេងក៏ដោយ ក៏សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ពុំមានន័យថា បញ្ជីទាំងនេះពុំមានសុពលភាពសម្រាប់សំណុំរឿង ០០២/០១ នោះទេ ហើយ សេចក្ដីសម្រេចនេះក៏ពុំបានតម្រូវឱ្យភាគីដាក់បញ្ជីថ្មីសម្រាប់សំណុំរឿង ០០២/០២ នោះក៏ទេ ដែរ។ សំណើសុំរួមពុំបានលើកឡើងអំពីឧបសគ្គតាមផ្លូវច្បាប់ណាមួយដែលរារាំងមិនឱ្យទទួល យកបញ្ជីឆ្នាំ ២០១១ ដែលអាចអនុវត្តបានដូចគ្នាចំពោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី អ្នក ជំនាញ និងឯកសារនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចបានគ្រោងទុកពីដំបូងមក នោះឡើយ។ ទឡ្ហីករណ៍នេះពុំបានផ្ដល់ជាមូលដ្ឋានដើម្បីសម្រេចថា ការជំនុំជម្រះនៅក្នុងសំណុំ រឿង០០២/០២ ទើបតែបានចាប់ផ្ដើមឡើងកាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ នោះទេ។

១០. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ម្ដងទៀតថា បញ្ជីឆ្នាំ ២០១១ បាន បំពេញតាមលក្ខខណ្ឌដែលបានចែងក្នុងវិធាន ៨០ នៃវិធានផ្ទៃក្នុង សម្រាប់គោលបំណងនៃ សំណុំរឿង ០០២/០២ ហើយវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងបានអនុវត្តចាប់តាំងពីពេលនោះ មក។ ទោះជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា ពេលវេលាយ៉ាងច្រើនបានកន្លង ផុតទៅហើយចាប់តាំងពីពេលដាក់បញ្ជីឆ្នាំ ២០១១ មក ហើយវាអាចមានទឡ្ហីករណ៍ខ្លះគាំទ្រ ឱ្យភាគីដាក់បំពេញបន្ថែម ក្នុងករណីពិសេស ទៅលើបញ្ជីឆ្នាំ ២០១១ ដោយពុំមានព្យសនកម្ម ឡើយ នៅមុនពេលចាប់ផ្ដើមសវនាការក្នុងសំណុំរឿង ០០២/០២ ដែលមានសារៈសំខាន់យ៉ាង ខ្លាំងនៅក្នុងការជំនុំជម្រះ។

១១. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងថ្លឹងថ្លែងអំពីភាពចាំបាច់ក្នុងការធានាថា ភស្តុតាងពាក់ព័ន្ធ និង អាចជឿទុកចិត្តបានទាំងអស់ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងគោលបំណងដើម្បី ជូនដំណឹងឱ្យបានទាន់ពេលអំពីភស្តុតាងបែបនេះ ដោយធានាឱ្យមានការជំនុំជម្រះមួយប្រកប ដោយយុត្តិធម៌ និងដើម្បីឱ្យការគ្រប់គ្រងការជំនុំជម្រះប្រកបដោយប្រសិទ្ធភាពរហូតដល់ទី បញ្ចប់។ មានឯកសារចំនួនរាប់នៅក្នុងបញ្ជីនៃសំណុំរឿង ០០២/០២ របស់ភាគី ដែលពុំត្រូវ បានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅមុនពេលចាប់ផ្ដើមការជំនុំជម្រះ កាលពីខែ មករា ឆ្នាំ ២០១១ នោះទេ។ ការដាក់លក្ខខណ្ឌឱ្យភាគីបញ្ជាក់មូលហេតុអំពីការខកខានក្នុងការដាក់ បញ្ចូលឯកសារទាំងនេះនៅក្នុងបញ្ជីឆ្នាំ ២០១១ របស់ពួកគេ និងក្រោយមកវាយតម្លៃលើ ឯកសារដោយផ្អែកតាមមូលដ្ឋានលើលក្ខណៈវិនិច្ឆ័យក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនឹងត្រូវ ចំណាយពេលវេលាច្រើន។ ម្យ៉ាងវិញទៀត គ្មានភាគីណាមួយជំទាស់ទៅនឹងត្រឹមត្រូវនៃការ

វាយតម្លៃលើភាពអាចទទួលយកបាននៃឯកសារដែលបានស្នើឡើងនៅក្នុងសំណុំរឿង ០០២/០២ ដោយពុំចាំបាច់យោងលើវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ។ ផ្អែកតាម កាលៈទេសៈទាំងនេះ ការតម្រូវឱ្យភាគីបង្ហាញថា ឯកសារទាំងនេះពុំអាចរកបាននៅមុនពេលជំនុំជម្រះ ពុំសមស្របតាមគោលបំណងរបស់វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនេះឡើយ។ ហេតុដូច្នេះ យោងតាមករណីពិសេសបែបនេះ អង្គជំនុំជម្រះនឹងចាត់ទុកបញ្ជីឆ្នាំ ២០១៤ ដែលបានដាក់អនុលោមតាមឯកសារ E305 ថាជាសំណៅបញ្ជីឆ្នាំ ២០១១ ដែលបានកែសម្រួល ដោយពុំចាំបាច់អនុវត្តតាមលក្ខខណ្ឌនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ។ ជាការពិតណាស់ ឯកសារទាំងអស់ដែលស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះត្រូវបន្តបំពេញលក្ខខណ្ឌក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងដដែល។ ករណីពិសេសនេះ រាប់បញ្ចូលបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ឆ្នាំ ២០១៤ ដែលនឹងត្រូវពិចារណាថាជាបញ្ជីឆ្នាំ ២០១១ ដែលបានកែសម្រួល។

១២. សំណើសុំរួមនេះស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា "ភស្តុតាងថ្មី" សម្រាប់គោលបំណងនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង គឺជាភស្តុតាងដែលពុំមាននៅក្នុងសំណុំរឿង ឬ ពុំបានដាក់បញ្ចូលនៅក្នុងបញ្ជីរបស់ភាគីអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា ឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ*នៅមុន*ពេលចាប់ផ្តើមការជំនុំជម្រះ (ពោលគឺ ឯកសារដែលមាននៅក្នុងបញ្ជីអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ដែលបានដាក់នៅក្នុងឆ្នាំ ២០១១) ពុំចាំបាច់គោរពតាមលក្ខខណ្ឌក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ (ឯកសារ E190)។ ឯកសារទាំងអស់ដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ*ក្រោយ*ការចាប់ផ្តើមការជំនុំជម្រះត្រូវគោរពតាមលក្ខខណ្ឌនៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ដើម្បីឱ្យសវនាការដំណើរការទៅឱ្យបានឆាប់រហ័ស និងប្រកបដោយយុត្តិធម៌ អង្គជំនុំជម្រះពិចារណាថាបញ្ជីឆ្នាំ ២០១៤ របស់ភាគីដែលបានដាក់អនុលោមតាមឯកសារ E305 ថាជាសំណៅបញ្ជីឆ្នាំ ២០១១ ដែលបានកែសម្រួល ដែលពុំចាំបាច់អនុវត្តតាមលក្ខខណ្ឌចែងក្នុងវិធាន ៨៧(៤) នោះទេ ទោះបីជាបញ្ជីទាំងនេះបានដាក់ក្រោយការចាប់ផ្តើមការជំនុំជម្រះក៏ដោយ។ អង្គជំនុំជម្រះសូមគូសបញ្ជាក់ថា សំណើសុំដាក់ឯកសារថ្មី ឬ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មីណាមួយនៅចំពោះមុខអង្គជំនុំជម្រះនាពេលខាងមុខត្រូវបំពេញតាមលក្ខខណ្ឌនៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងជាកំហិត។

១៣. អនុស្សរណៈនេះគឺជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E307/1/1។